ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៣៤ សហវ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយ អភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដែលសរសេរជាអក្សរកាត់ថា **ក.គ.អ.ប.** ក្រោមឱវាទគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល ដែលសរសេរជាអក្សរកាត់ថា **គ.ស.ធ.ឌ.** ដែលមានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម ***រស់ សីលវ៉ា*** អនុប្រធានក្រុមប្រឹក្សា អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងជាសមាជិក **គ.ស.ធ.ឌ.** ប្រធាន

- ឯកឧត្តម **ផាន់ ផល្លា** សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អនុប្រធាន
- ឯកឧត្តម **ម៉ី វ៉ាន់** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន
  អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អនុប្រធាន
- ឯកឧត្តម **គង់ ម៉ារី** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ.** អនុប្រធានប្រចាំការ
- ឯកឧត្តម **អ៊ូ ចាន់សារា** អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា អនុប្រធាន
- ឯកឧត្តម **ហ៊ុយ វណ្ណៈ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម **សុខ សុភ័ក្រ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក
- ឯកឧត្តម **ភាន ច័ន្ទមេត្តា** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
  បច្ចេកវិទ្យា និងនវានុវត្តន៍ សមាជិក
- ឯកឧត្តម **ពិត ចំណាន** រដ្ឋលេខាធិការប្រចាំការក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- ឯកឧត្តម **ជីវ សុខហាក់** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- ឯកឧត្តម **ខូវ មករា** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
- ឯកឧត្តម **ហុង ជឿន** រដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
  នៃនិយ័តករមូលបត្រកម្ពុជា សមាជិក
- ឯកឧត្តម **ចន ណារិទ្ធ** អគ្គនាយកនៃនិយ័តករសន្តិសុខសង្គម សមាជិក
- ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច សមាជិក
- ឯកឧត្តម **ម៉ូ ចារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម សមាជិក
- ឯកឧត្តម **ម៉ូ ច័ន្ទតីរ្វ** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា សមាជិក
- ឯកឧត្តម **ជូ វណ្ណៈ** អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ សមាជិក
- ឯកឧត្តម **ឈាង វណ្ណារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ
  នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **តាំង ខូនលី** នាយកប្រតិបត្តិមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សមាជិក
- ឯកឧត្តម **ឈៀង វណ្ណមុនិណ្ណ** ទីប្រឹក្សាឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
- លោក **លឹម ជីលុច** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ
  នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោក **ជា ភុកហុង** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ
  នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោក **អៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- លោក **ឈន ធឿន** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
  នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

- លោក **ស៊ូ សុភា** ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុ
  នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សមាជិក។

**ក.គ.អ.ប**.អាចមានសមាសភាពបន្ថែមជាប្រធានស្ថាប័ន តំណាងឬមន្ត្រីក្រសួង-ស្ថាប័នឬអង្គភាពពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាលតាមការចាំបាច់។

សមាសភាពបន្ថែមនៃ **ក.គ.អ.ប**. ត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់ប្រធាន **គ.ស.ធ.ឧ**.។

**ប្រការ២.-**

**ក.គ.អ.ប**.មានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

- រៀបចំសេចក្ដីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា
- ពិនិត្យ សិក្សា ស្រាវជ្រាវ វិភាគ និងវាយតម្លៃក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ ស្ថាប័ន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងក្របខណ្ឌបច្ចេកទេស ពាក់ព័ន្ធការកសាង ការអភិវឌ្ឍ និងការធ្វើនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងបរិការណ៍កម្ពុជា តំបន់ និងសកល
- ពិនិត្យ តាមដាន សិក្សា ស្រាវជ្រាវ វិភាគ និងវាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយ កាលានុវត្តភាព សក្ដានុពល និងការគំរាមកំហែងឬបញ្ហាប្រឈម ព្រមទាំងឧត្តមានុវត្តន៍ ស្ថានភាព និង/ឬនិន្នាការនៃការកសាង ការអភិវឌ្ឍ និងការធ្វើនិយ័តកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងបរិការណ៍កម្ពុជា តំបន់ និងសកល
- ពិនិត្យ សិក្សា ស្រាវជ្រាវ វិភាគ និងវាយតម្លៃជាអាទិ៍ហេដ្ឋារចនាសម្ព័ន្ធ ទំនុកចិត្តនិងភាពជឿជាក់ តម្រូវការធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានបច្ចេកទេស បច្ចេកវិទ្យា ឌីជីថលូបនីយកម្ម គំរូធុរកិច្ចថ្មី ព្រមទាំងកិច្ចសហប្រតិបត្តិការ ក្នុងបរិការណ៍កម្ពុជា តំបន់ និងសកល សំដៅធានាស្ថិរភាព ការការពារវិនិយោគិននិងអតិថិជន/អ្នកប្រើប្រាស់ បរិយាបន្នកម្ម សុចរិតភាព ការប្រកួតប្រជែងស្មោះត្រង់ និងនវានុវត្តន៍ ក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ
- សហការជាមួយនឹងក្រសួង-ស្ថាប័នឬអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីពិនិត្យ សិក្សា និងស្នើសុំជាតុចូលបន្ថែម សំដៅធានាសង្គតិភាពរវាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាជាមួយនឹងគោលនយោបាយពាក់ព័ន្ធ
- ដឹកនាំ សហការ សម្របសម្រួល និងរៀបចំកិច្ចប្រជុំនិង/ឬសិក្ខាសាលាពិគ្រោះយោបល់ជាមួយនឹងក្រសួង-ស្ថាប័នឬអង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជន ព្រមទាំងធ្វើទស្សនកិច្ចសិក្សា ដើម្បីទាញយកបទពិសោធនិងប្រមូលធាតុចូលបន្ថែម តាមការចាំបាច់
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារ។

**ប្រការ៣.-**

**ក.គ.អ.ប**.ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីដែលប្រធាន **ក.គ.អ.ប**. អវត្តមានឬមានករណីចាំបាច់ ប្រធាន **ក.គ.អ.ប**. អាចផ្ទេរសិទ្ធិជូនអនុប្រធានប្រចាំការឬអនុប្រធានណាមួយដើម្បីដឹកនាំកិច្ចប្រជុំ។

សមាជិក **ក.គ.អ.ប**. ដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់តំណាងក្នុងនាមក្រសួង-ស្ថាប័នឬអង្គភាពខ្លួនដើម្បីចូលរួមប្រជុំជំនួស។

**ប្រការ៤.-**

ប្រធាន **ក.គ.អ.ប**. ឬអនុប្រធានប្រចាំការឬអនុប្រធាន **ក.គ.អ.ប**. ដែលទទួលសិទ្ធិដឹកនាំកិច្ចប្រជុំពីប្រធាន **ក.គ.អ.ប**. មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់ ឥស្សរជន មន្ត្រីជំនាញ តំណាងក្រសួង-ស្ថាប័ន ឬអង្គភាព ដៃគូអភិវឌ្ឍ និងវិស័យឯកជន ដែលមានបទពិសោធ សមត្ថភាព និងជំនាញវិជ្ជាជីវៈ ចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ **ក.គ.អ.ប**. តាមការចាំបាច់។

**ប្រការ៥.-**

**ក.គ.អ.ប**.អាចមានក្រុមការងារបច្ចេកទេសមួយចំនួនជាសេនាធិការក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។ ការបង្កើតក្រុមការងារបច្ចេកទេសទាំងនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ស.ធ.ឧ**.។

**ប្រការ៦.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឧ**. និងប្រធានអង្គភាពដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ រោច ខែ មាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាន គ.ស.ធ.ឧ.**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ